ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពជំនាញការពាររុក្ខជាតិ

# សេចក្តីជូនដំណឹងសំខាន់ៗ

## អំពីរុក្ខជាតិនៅក្នុងអីវ៉ាន់យួរដៃ

ក្នុងករណីគ្មានការប្រកាសនាំចូល ឬនាំយករុក្ខជាតិចូលដោយខុសច្បាប់

## អ្នកនឹងត្រូវរងការពិន័យ។

◆ ដាច់ខាតត្រូវមកកាន់បញ្ជរភូតគាមអនាម័យ មុនពេលត្រួតពិនិត្យគយ។

សូមជ្រាបពីចំណុចខាងក្រោមទាក់ទងនឹងរុក្ខជាតិដែលនាំចូលមកក្នុងប្រទេសជប៉ុនជាអីវ៉ាន់យួរដៃ។

1. អ្នកត្រូវប្រកាសអំពីរុក្ខជាតិនៅលើទម្រង់ប្រកាសទំនិញយកតាមខ្លួននិងទំនិញផ្ញើដោយឡែក(ទម្រង់ប្រកាសគយ)។
2. **ប្រភេទគ្រាប់ពូជដូចជា កូនឈើ គ្រាប់ដំណាំជាដើម ទងផ្កា បន្លែ ផ្លែឈើ សណ្តែក ស្រូវ ។ល។** ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រភូតគាមអនាម័យដែលចេញដោយស្ថាប័នរដ្ឋនៃប្រទេសនាំចេញ។
3. រុក្ខជាតិដែលត្រូវបានហាមឃាត់មិនឱ្យយកចូលនឹងត្រូវបោះចោល។

◆ នៅពេលចុះបញ្ជីព័ត៌មានលិខិតឆ្លងដែន និងប័ណ្ណឡើងយន្តហោះក្នុងនីតិវិធីត្រួតពិនិត្យការនាំចូល គេត្រូវការពេលវេលាដើម្បីត្រួតពិនិត្យ។

ក្នុងករណីអ្នកនាំទំនិញហាមឃាត់នាំចូល ឬរុក្ខជាតិចូលមកដោយខុសច្បាប់ អនុលោមតាមច្បាប់ការពាររុក្ខជាតិ ពួកវានឹងត្រូវបោះចោល ហើយអ្នកអាចនឹងត្រូវរងការផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ 3ឆ្នាំ ឬពិន័យជាប្រាក់រហូតដល់ 3លានយ៉េន។

សូមមើលនៅទីនេះដើម្បីដឹងថាអ្នកអាចនាំយករុក្ខជាតិចូលបានឬទេ!

សូមមើលនៅទីនេះ សម្រាប់វិញ្ញាបនបត្រភូតគាមអនាម័យ!

## លេខទំនាក់ទំនងចម្បងនៃអង្គភាពជំនាញការពាររុក្ខជាតិ

- អង្គភាពជំនាញការពាររុក្ខជាតិយ៉ូកូហាម៉ា 045−211−7153
- អង្គភាពជំនាញការពាររុក្ខជាតិម៉ុជិ 093−321−2601
- អង្គភាពជំនាញការពាររុក្ខជាតិណាហ្គោយ៉ា 052−651−0112
- អង្គភាពជំនាញការពាររុក្ខជាតិណាហា 098−868−2850
- អង្គភាពជំនាញការពាររុក្ខជាតិកូបិ 078−331−2386

MAFF
Ministry of Agriculture, Forestry and Fisheries
農林水産省

កំពុងប្រុងប្រយ័ត្នលើការឈ្លានពានចូលនៃសត្វល្អិតចង្រៃពីរុក្ខជាតិ